# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

## រយៈពេល ៣ ឆ្នាំ

## (២០១៧ - ២០១៩)

ឈ្មោះសហគមន៍ : ដូនស្តើង

ភូមិ : ដូនស្តើង

ឃុំ : ពាមបាង

ស្រុក : ស្ទោង

ខេត្ត : កំពង់ធំ

## មាតិកា


**១. ស្ថានភាពទូទៅ** ........ 4

**២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម** ........ 5

ក- ប្រជាពលរដ្ឋ ........ 5

ខ-មុខរបរ ........ 5

**៣. កន្លែងនេសាទសហគមន៍ និង ធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ........ 5

ក. ទីតាំង ........ 5

ខ. ដែននេសាទ ........ 6

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ 6

ឃ. ធនធានជលផល ........ 6

**៤. ការធ្វើនេសាទ** ........ 7

ក. អ្នកនេសាទ ........ 7

ខ. ឧបករណ៍នេសាទ ........ 7

គ. ប៉ាន់ប្រមាណផលចាប់នេសាទប្រចាំឆ្នាំ ........ 9

**៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ........ 9

ក. ទស្សនៈវិស័យ ........ 9

ខ. គោលបំណង ........ 9

គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ 9

គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ 9

គ.២ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ........ 11

គ.៣ ផែនការគ្រប់គ្រងព្រៃលិចទឹក ........ 12

គ. ៤ ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ 12

គ. ៥ ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍ ........ 12

គ. ៦ ផែនការបង្កើនមុខរបរចិញ្ចឹមជីវិត ........ 13

គ. ៧ ផែនការពង្រឹងសម្ថភាពគណៈកម្មការសហគមន៍នេសាទ ........ 14

គ. ៨ ផែនការទិញទូកម៉ាស៊ីនចុះល្បាត ..... 15
គ.៩ ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ ..... 15
ឃ. យុទ្ធសាស្ត្រ ..... 15
**តារាងសង្ខេបផែនការគ្រប់គ្រងតំបន់ខ្លែងនេសាទសហគមន៍ដូនស្តើង រយៈពេល (២០១៧ ដល់ ២០១៩)** ..... 17
**តារាងសង្ខេបការងារ** ..... 21

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទដូនស្ដើង ត្រូវបានបង្កើតឡើង ដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០០៧ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០០៧ ។

សហគមន៍នេសាទដូនស្ដើង មានទីតាំងស្ថិតនៅភូមិដូនស្ដើង ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ ដែលមានសមាជិកសរុបចំនួន២៣០ នាក់ ស្ត្រីចំនួន១១៦នាក់ និងមានគណៈកម្មការចំនួន ៧នាក់ ស្ត្រីចំនួន០នាក់ ក្នុងនោះចំនួនគ្រួសារសរុបចំនួន ១២០ គ្រួសារ ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួនរួមមានៈ

- បានប្រជុំពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ អាជ្ញាធរភូមិ ឃុំ សមត្ថកិច្ចរដ្ឋបាលជលផល និងអ្នកពាក់ព័ន្ធដើម្បីរៀបចំកំណត់ព្រំប្រទល់ និងធ្វើផែនទីកន្លែងនេសាទសហគមន៍ ។
- ផ្សព្វផ្សាយអំពីលិខិតបទដ្ឋានពាក់ព័ន្ធនឹងសហគមន៍នេសាទដល់សមាជិកសហគមន៍នេសាទ និងអ្នកចូលរួមមកប្រើប្រាស់ធនធានជលផលក្នុងកន្លែងនេសាទសហគមន៍។
- សហការជាមួយអាជ្ញាធរភូមិ ឃុំ និងសមត្ថកិច្ចរដ្ឋបាលជលផល ចុះល្បាត ការពារ ទប់ស្កាត់បទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍។
- ផ្សព្វផ្សាយអំពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ និងទទួលពាក្យសុំចូលជាសមាជិកសហគមន៍នេសាទដោយស្ម័គ្រចិត្តបង់ប្រាក់សមាជិកភាពរបស់សហគមន៍នេសាទ។
- រៀបចំសេចក្តីព្រៀងកន្លែងសហគមន៍នេសាទសហគមន៍ និងចុះកិច្ចព្រមព្រៀងកន្លែងនេសាទជាមួយខ័ណ្ឌរដ្ឋបាលជលផល ។
- រៀបចំផែនការគ្រប់គ្រងសហគមន៍នេសាទ ឆ្នាំ ២០០៧ ដល់ ឆ្នាំ ២០០៩, និងឆ្នាំ ២០០៩ ដល់ ឆ្នាំ ២០១១។
- បានរៀបចំបណ្ដាញគណៈកម្មការសហគមន៍នេសាទ ឃុំ និងចូលរួមជាមួយបណ្ដាញថ្នាក់ស្រុក ខេត្ត និងតំបន់ជាមួយខេត្តកំពង់ឆ្នាំងក្នុងកំរិតគម្រោងអភិវឌ្ឍន៍ធនធានជលផល និងជីវភាពប្រកបដោយនិរន្តរភាព និងបរិយាប័ន្ន (EU-SIFAL)។
- គណៈកម្មការសហគមន៍នេសាទបានចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីឧបករណ៍វិភាគសហគមន៍ និងការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ។
- ចូលរួមទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ នៅខេត្តសៀមរាប សហគមន៍នេសាទកំពង់ភ្លុក ជ្រាវ និងកែវពណ៌។
- ចូលរួមប្រជុំជាមួយបណ្ដាញថ្នាក់ជាតិដើម្បីចែករំលែកពត៌មាន បទពិសោធន៍ និងបទដ្ឋានគតិយុទ្ធស្ដីពីជលផល។

- ចូលរួមទប់ស្កាត់បទល្មើសនេសាទជាមួយសង្កាត់រដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ និងចុះល្បាតក្នុងដែនអភិរក្សសហគមន៍នេសាទ។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក- ប្រជាពលរដ្ឋ

- ចំនួនសមាជិកសរុបក្នុងសហគមន៍នេសាទមាន ៦១៦ នាក់ ប្រុស ២៩៨នាក់ ស្រី៣១៨នាក់ ។ ក្នុងនោះមានជនជាតិខ្មែរចំនួន ៦១៤នាក់ ខ្មែរឥស្លាមចំនួន ០នាក់ និងអណិកជនវៀតណាមចំនួន៨នាក់។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ២៥នាក់។
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ៥នាក់ ស្រី១នាក់។
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៣០នាក់ ស្រី ២០ នាក់។
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ០១នាក់ ស្រី ០ នាក់។
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទមានចំនួន ២០នាក់ ស្រី ១២ នាក់។
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់ព្រះពុទ្ធសាសនា១០០% ។
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន៣១៦នាក់ ស្រី ១៧០ នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន ១៧៧នាក់ ស្រី ៨៤នាក់ និងកំរិតមធ្យមសិក្សាចំនួន ៧៧នាក់ ស្រី ៣០នាក់។

### ខ-មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន ៖

- ធ្វើនេសាទចំនួន ១២០គ្រួសារ
- ធ្វើវារីវប្បកម្ម ចំនួន ៤០គ្រួសារ (ចិញ្ចឹមត្រីប្រាក្នុង ៤០បែ)
- ជាងទូកចំនួន ២ គ្រួសារ
- លក់ដូរចំនួន ៨គ្រួសារ
- ទិញត្រីចំនួន ៥គ្រួសារ
- ចិញ្ចឹមជ្រូក ៥គ្រួសារ
- បញ្ចូលអាគុយ ៤ គ្រួសារ ។

## ៣. កន្លែងនេសាទសហគមន៍ និង ធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍ជូនស្ទើង ជាកន្លែងដែលត្រូវបានកាត់បន្ថយចេញពីឡូត៍នេសាទលេខ៥ខេត្តកំពង់ធំ។

កន្លែងនេសាទសហគមន៍ជូនស្ទើង មានទំហំ ៤៤៤ ហិកតា និងមានកំណត់និយាមកា ដូចមានចែងក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់:

- ខាងជើងទល់ទន្លេធ្លារ និងឡូត៍លេខ៦
- ខាងត្បូងទល់នឹងឡូត៍នេសាទ លេខ ៥
- ខាងកើតទល់នឹងឡូត៍នេសាទលេខ ៦
- ខាងលិចទល់នឹងសហគមន៍នេសាទ៣មបាង ។

ខ. ដែននេសាទ

- កន្លែងនេសាទសហគមន៍ដូនស្តើងមានព្រែកចំនួន ៣ ព្រៃលិចទឹកចំនួន ៦ និងទំនាបលិចទឹក ៦កន្លែង ។
- ព្រែកឈ្មោះអន្លង់កញ្ជុះ ប្រវែង ២០០០ម៉ែត្រ នេសាទពីខែមករា ដល់ខែធ្នូ
- ព្រែកឈ្មោះអន្លង់ផ្តៅលប្រវែង ២៥០០ ម៉ែត្រ នេសាទពីខែ មករា ដល់ ខែធ្នូ
- ព្រែកឈ្មោះអន្លង់តាអោន ប្រវែង ២០០០ ម៉ែត្រ នេសាទពីខែមករា ដល់ ខែ ធ្នូ
- ព្រៃលិចទឹកមានទំហំសរុប ២១៨,៦២ ហិកតា
- ព្រៃឈ្មោះ ព្រៃអន្លង់ផ្តៅលខាងត្បូង ទំហំ ៨ហិកតា
- ព្រៃឈ្មោះ ព្រៃបណ្តាចារ ទំហំ ៣៤,៤៨ហិកតា
- ព្រៃឈ្មោះ ព្រៃចងខ្លួង ទំហំ ៤,០៧ហិកតា
- ព្រៃឈ្មោះ ព្រៃអន្លង់ផ្តៅល ទំហំ ៩៩,១០ហិកតា
- ព្រៃឈ្មោះ ព្រៃដូនស្តើង ទំហំ ២៣,១៦ហិកតា
- ព្រៃឈ្មោះ ព្រៃអន្លង់តាអោនទំហំ ៤៨,៨១ហិកតា
- ដីទំនាបលិចទឹកមានទំហំសរុប៨៨,៨៦ហិកតា

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

- អន្លង់ឈ្មោះ កន្លែងអភិរក្សត្រីមេពូជអន្លង់តាអោន ទំហំ ៣ហិកតា (បណ្តោយ ២៧០ម៉ែត្រ ទទឹង ១១០ម៉ែត្រ)
- ព្រៃឈ្មោះ កន្លែងអភិរក្សព្រៃលិចទឹកអន្លង់ផ្តៅលខាងត្បូងទំហំ ៨ហិកតា
- ព្រៃឈ្មោះ កន្លែងអភិរក្សព្រៃលិចទឹកបណ្តាចារ ទំហំ ៣៤,៤៨ ហិកតា
- ព្រៃឈ្មោះ កន្លែងអភិរក្សព្រៃលិចទឹកចងខ្លួង ទំហំ ៤,០៧ហិកតា
- ព្រៃឈ្មោះ កន្លែងអភិរក្សព្រៃលិចទឹកអន្លង់ផ្តៅលទំហំ ៩៩,១០ហិកតា
- ព្រៃឈ្មោះ កន្លែងអភិរក្សព្រៃលិចទឹកដូនស្តើងទំហំ ២៣, ១៦ហិកតា
- ព្រៃឈ្មោះ កន្លែងអភិរក្សព្រៃលិចទឹកអន្លង់តាអោនទំហំ ៤៩,៨១ហិកតា

ឃ. ធនធានជលផល

- ប្រភេទត្រី ( ត្រីឆ្តោ រ៉ស់ ខ្នាន់ កំភ្លាញ រៀល ឆ្ពិន ក្រាញ់ កញ្ជុះ តាអោន ឆ្លាំង កន្ទ្រប់ គ្រំ ក្អែក ព្រួល ក្រសក់ កន្ទ្រង់ព្រេង ក្រុស ក្រហែ កញ្ច្រូក ស្រកាក្តាម ស្លឹកឫស្សី ឆ្ពួញ ដំរី អណ្តាតឆ្កែ លិញ ប្រម៉ា កញ្ជុះភ្លោង ច្រកែង ឆ្កៀត កំភ្លៀវ អណ្តែង ត្បក ស្រកៀតស្រង់ ប្រា ពោ ស្លាត ក្រាយ ត្រីម កំព្រាម កញ្ចនជ័យ កញ្ជុះគ្របី ខ្ទឹង កញ្ជុះជ្រូក ត្រនេល ព្រលូង កេស ក្រម៉ម គល់រាំង ចង្វារ ត្រចៀកស្វា ដងខ្វែង ឆ្តោក កាបក្បាលធំ កន្ទ្រប់ខ្លា.....)

- ប្រភេទវារីសត្វ ( អណ្តើក ពស់ថ្លាន់ ពស់ព្រលិត ពស់ត្រី ក្តាម ខ្យង ខ្ចៅ អន្ទង់ កន្ធាយ អន្សង់ ត្រុំ លៀស កំពឹស......
- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារុក្ខជាតិ (រាំង ក្រស់ ត្រសែង ត្នួ ផ្តោល ទៀនព្រៃ ឈើយ ញ. រញ ផ្ទុរ គ្រពស់ សំរ៉ែក សង្ឃរ ភ្នំភ្លែង ថ្វាន់ ភ្លែកព្រាប ខ្នាយមាន់ ថ្លើមអណ្តើក អញ្ចាញ ប្រកែង សណ្តាន់ រំដិញ អាវក្រពើ ត្រដក់ ប្រផិញ ចាប៉ូវ ចាទៃ ផ្តាប់ ត្រឡក បាយដំណើប វល្លិ៍ព្រេង ត្រជិត បន្លាយួន កណ្តាប់ចង្កេរ ឆ្អឹងពស់ មុខឈ្លាង ស្នោ ក្រទាំងហៃ ឈូក ស្ពន់ កំពឹងពួយ ដើមវែ ស្លត បបោស ព្រលិត ត្រកួន កំប្លោក ស្រងែ ស្លាបទា កាផែត កំពឹងពួយ សារ៉ាយ ចក ចំផ្លង......) ។

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ២៣០នាក់ ស្រី ១១៦នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍ចំនួន ៣០០នាក់ ស្រី ១៧០នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិក ដែលមកពីក្រៅសហគមន៍មានចំនួន ១៥០នាក់ ស្រី៥០នាក់។

### ខ. ឧបករណ៍នេសាទ

- ឧបករណ៍នេសាទ និងទូកកាណូតសហគមន៍:

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ. ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មង | ១ថង់ = ៩០ម | ៣ថង់x២៣០ន | -ក្រឡា=៣,៥ស.ម<br>-សំរុង=១,២ម<br>-ប្រវែង=៦៩០ម | ខែ១០ ទៅ ខែ ៦ |
| អួន | វង់ = ៨០ម | ៤០=(១វង់x៤០ន) | -ក្រឡា=១,៥ស.ម<br>-សំរុង=៣ម<br>-ប្រវែង៣២០០ម | ខែ៤ ទៅ ខែ ៦ |
| សន្ទូចរនង | សាង =៣០០ផ្លែ | ៦០សាង | - ផ្លែលេខ=១១-១៣<br>- ចំនួន=១៨០០០ផ្លែ | ខែ៧ ទៅ ខែ ១២ |
| លបទល់ | គ្រឿង | ២៨០=(៤០x៧ន) | - មុខកាត់=៤០ស.ម<br>- បណ្តោយ=១,២ម | ខែ១ ទៅ ខែ ៣ |
| សំណាញ់ | វង់ | ២៥ | - ក្រឡា=១,៥ស.ម<br>- សំរុង=៦ម | ខែ១ ទៅ ខែ ១២ |
| លបលុង | គ្រឿង | ៣០០=(៣០x១០ន) | -ទទឹង=0,៦០ស.ម<br>-បណ្តោយ=១,២ម<br>-ក្រឡាគ្រៀម=៣ស.ម | ខែ៥ ទៅ ខែ ៨ |

| | | | | |
|---|---|---|---|---|
| លាន់ | គ្រឿង | ៧៥០=(៥០x១៥ន) | - មុខកាត់=១០ស.ម<br>- បណ្តោយ=១,៥ម | ខែ ៥ ទៅ ខែ ១២ |
| ឡើ | គ្រឿង | ១២០០=(៣០x៤០ន) | - មុខកាត់=២៥ស.ម<br>- បណ្តោយ=០,៥០ម | ខែ ៧ ទៅ ខែ ១២ |
| លបញ្ជីក | គ្រឿង | ៩០=(៣x៣០ន) | - មុខកាត់=២៥ស.ម<br>- បណ្តោយ=០,៥០ម<br>- ក្រឡាត្រៀម=១,៥ | ខែ ៦ ទៅ ខែ ៧ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកអុំ | ១០០ | ១០០-៣០០គីឡូក្រាម | |
| ទូកម៉ាស៊ីន | ៣០០ | ២០០-៥០០គីឡូក្រាម | ៥-១៥ |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទៈ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ. ប្រវែង |
|---|---|---|---|
| មង | ១ថង់=៩០ម | ៤៥០០=(២ថង់x២៥នាក់) | -ក្រឡា=៣,៥ស.ម<br>-សំរុង=១,២ម<br>-ប្រវែង=៤៥០០ម |
| អួន | វង់=៨០ម | ១០វង់ | -ក្រឡា=១,៥ស.ម<br>-សំរុង=៣ម<br>-ប្រវែង=៨០០ម |
| លបញ្ជីក | គ្រឿង | ១៥=(៣x៥ន) | - មុខកាត់=២,៥ស.ម<br>- បណ្តោយ=០,៥០ម<br>- ក្រឡាត្រៀម=១,៥ |
| លបទល់ | គ្រឿង | ១៤០០=(៤០x១១នាក់) | -ទទឹង=០,៦០ម<br>-បណ្តោយ=១,២ម |
| លបលួង | គ្រឿង | ៣០០=(៣០x១០ន) | -ទទឹង=០,៦០ស.ម<br>-បណ្តោយ=១,២ម<br>-ក្រឡាត្រៀម=៣ស.ម |

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ. ប្រវែង |
|---|---|---|---|
| លបត្រីកញ្ចុះ | គ្រឿង | ២៥០=(១០x២៥ន) | -ទទឹង=៣០ស.ម<br>-បណ្តោយ =១ម |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកអុំ | ៥០ | ១០០-៣០០គឡូមក្រាម | |
| ទូកម៉ាស៊ីន | ២៥ | ២០០-៥០០គីឡូក្រាម | ៥-១៥ |

គ. ប៉ាន់ប្រម៉ាណផលចាប់នេសាទប្រចាំឆ្នាំ

| ប្រភេទលផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ *(គិតជា គក)* | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៦០ | ៤០ | ១០០ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ក. ទស្សនៈវិស័យ

សហគមន៍នេសាទជូនស្ទើង មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាសហគមន៍ ។

ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាប ដែលបានកាត់បន្ថយពីនាទីឡូត៍នេសាទលេខ៥របស់ខេត្តកំពង់ធំ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី និងនាទីព្រៃលិចទឹក។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាសហគមន៍ប្រកបដោយសមធម៌។
- ដើម្បីធ្វើអោយប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍចម្រុះ ដោយមានការចូលរួម។
- ដើម្បីអោយប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ ។

គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។ ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

| ឈ្មោះ/ទីតាំង/កន្លែងនេសាទ | ពេលវេលាថ្ងៃនេសាទ | ឧបករណ៍នេសាទអនុញ្ញាតអោយប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| ព្រែកអន្លង់កញ្ចុះ | ១ - ១២ | មង | -ក្រឡាចាប់ពី២,៥ស.ម<br>-ប្រវែង=៣០០ម | ២០នាក់ | |
| | ៤ - ៥ | អួន | -ក្រឡា=១,៥ស.ម<br>-សំរុង=៣ម<br>-ប្រវែង=៤០០ម | ៣នាក់ | |
| | ៩ - ១០ | សំណាញ់ | -ក្រឡាលើសពី១,៥ស.ម<br>-សំរុង=៦ម | ១០នាក់ | |
| | ១ - ៣ | លប់ទល់ | -ទទឹង=០,៦០ម<br>-បណ្តោយ=១,២ម | ៤នាក់ | |
| | ៥ - ៧ | លបលួង | -ទទឹង=០,៦០ស.ម<br>-បណ្តោយ=១,២ម<br>-ក្រឡាត្រៀម=៣ស.ម | ៣នាក់ | |
| | ៨ - ២ | ឡើ | - មុខកាត់=២៥ស.ម<br>- បណ្តោយ=០,៥០ម | ១០នាក់ | |
| | ៦ - ៧ | លបញឹក | - មុខកាត់=២៥ស.ម<br>- បណ្តោយ=០,៥០ម<br>- ក្រឡាត្រៀម=១,៥ស.ម | ៧នាក់ | |
| ព្រែកអន្លង់ថ្លោល | ១ - ១២ | មង | -ក្រឡាចាប់ពី២,៥ស.ម<br>-សំរុង=១,២ម<br>-ប្រវែង=៣០០ម | ២០នាក់ | |
| | ៤ - ៥ | អួន | -ក្រឡា=១,៥ស.ម<br>-សំរុង=៣ម<br>-ប្រវែង=៤០០ម | ៣នាក់ | |
| | ៩ - ១០ | សំណាញ់ | - ក្រឡាលើសពី១,៥ស.ម<br>- សំរុង=៦ម | ១០នាក់ | |
| | ១ - ៣ | លប់ទល់ | -មុខកាត់=០,៤០ស.ម<br>បណ្តោយ=១,២ម | ៤នាក់ | |
| | ៥ - ៧ | លបលួង | -ទទឹង=០,៦០ស.ម<br>-បណ្តោយ=១,២ម<br>-ក្រឡាត្រៀម=៣ស.ម | ៣នាក់ | |
| | ៨ - ២ | ឡើ | | ១០នាក់ | |
| | ៦ - ៧ | លបញឹក | | ៧នាក់ | |

| | | | | | |
|---|---|---|---|---|---|
| | ១ - ១២ | មង | -ក្រឡាចាប់ពី២.៥ស.ម<br>-ប្រវែង=៣០០ម | ២០នាក់ | |
| | ៤ - ៥ | អួន | -ក្រឡា=១,៥ស.ម<br>-សំរុង=៣ម<br>-ប្រវែង=៨០០ម | ៣នាក់ | |
| | ៩ - ១០ | សំណាញ់ | ក្រឡាលើសពី១,៥ស.ម | ១០នាក់ | |
| ព្រៃកអន្លង់តាអោន | ១ - ៣ | លប់ទល់ | -មុខកាត់=០,៤០ស.ម<br>-ទទឹង=០,៦០ម<br>បណ្ដោយ=១,២ម | ៤នាក់ | |
| | ៥ - ៧ | លបលួង | -កំពស់=០,៦០ស.ម<br>-បណ្ដោយ=០,៦០ម<br>ក្រឡាត្រៀម=០,៣ស.ម | ៣នាក់ | |
| | ៨ - ២ | ឡើ | - មុខកាត់=២៥ស.ម<br>- បណ្ដោយ=០,៥០ម | ១០នាក់ | |
| | ៦ - ៧ | លបញីក | - មុខកាត់=២៥ស.ម<br>- បណ្ដោយ=០,៥០ម<br>- ក្រឡាត្រៀម=១,៥ | ៧នាក់ | |

**គ.២ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស**

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស និងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ (ហិកតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| អន្លង់តាអោន | ៣ហិកតា<br>ប=២៧០ម<br>ទ=១១០ម | អន្លង់អភិរក្សត្រីមេពូជ | -ធ្វើស្លាកសញ្ញាអភិរក្សត្រីមេពូជ និងធ្វើបង្គោលព្រំកន្លែងអភិរក្ស<br>-ប្រជុំផ្សព្វផ្សាយអំពីកន្លែងអភិរក្សត្រីមេពូជ<br>-បង្កើតជម្រកសប្បនិម្មិតកន្លែងអភិរក្សត្រីមេពូជ<br>-ចុះល្បាតការពារកន្លែងអភិរក្សត្រីមេពូជជាប្រចាំ | ៧/២០១៧ | ៨/២០១៧ | |
| ព្រៃអន្លង់ថ្មោលខាងត្បូង | ៨ | អភិរក្សព្រៃលិចទឹក | -ធ្វើស្លាកសញ្ញាអភិរក្សព្រៃលិចទឹក | ៧/២០១៧ | ៨/២០១៧ | |

| | | | | | | |
|---|---|---|---|---|---|---|
| ព្រៃបណ្ដាចារ | ៣៤,៤៨ | | -ប្រជុំផ្សព្វផ្សាយអំពីកន្លែងអភិរក្សព្រៃលិចទឹក<br>-កំណត់ និងបោះបង្គោលព្រំប្រទល់កន្លែងអភិរក្ស<br>-ចុះល្បាត ការពារកន្លែងអភិរក្សព្រៃលិចទឹក | | | |
| ព្រៃចងខ្លង | ៤,០៧ | | | | | |
| ព្រៃអន្លង់ផ្ដោល | ៩៩,១០ | | | | | |
| ព្រៃជូនស្ទើង | ២៣,១៦ | | | | | |
| ព្រៃអន្លង់តាអោន | ៤៩,៨១ | | | | | |

គ.៣ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមានក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំ | ទំហំ (ហិកតា) | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១.ដាំព្រៃលិចទឹកទួលកោះយាយស្ដេង | ៧,៨៦ | -កូនរាំង<br>-កូនផ្ដោល | -ធ្វើថ្នាលផ្សាំកូនដើមរាំង និងកូនដើមផ្ដោល<br>-រៀបចំកន្លែងដែលត្រូវដាំកូនដើមរាំង និងផ្ដោល<br>-រៀបចំដាំដើមឈើចំនួន ១៥០០០ដើម | ៥/២០១៨ | ៦/២០១៨ | |

គ. ៤ ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវអភិវឌ្ឍន៍ដូចខាងក្រោមៈ

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្ដើម | ប្រមូលផល |
| បែ (ប:៦ម ទ:៣,៥ម) | ១០ | ត្រីអណ្ដែង | ៤០០០០ (១ស្រះ=៤០០០ក្ប) | ១ មករា ២០១៨ | ១/១០/២០១៨ |
| បែ (ប:១០ម ទ:៧ម) | ១០ | ប្រា | ២៥០០០ក (១ស្រះ=២៥០០ក) | ១ មករា ២០១៨ | ១/១០/២០១៨ |

គ. ៥ ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ពេលចាប់ផ្ដើម | ពេលបញ្ចប់ | ចំណាយសរុប | ផ្សេងៗ |
|---|---|---|---|---|---|

| | | | | | |
|---|---|---|---|---|---|
| វិភាគទានពីសមាជិកសហគមន៍ | -ផ្សព្វផ្សាយអំពីការដាក់ពាក្យសុំចូលសមាជិក<br>-ទទួលពាក្យនិងប្រមូលប្រាក់បង់សមាជិកភាព | ១/១២/២០១៧ | ២៥/១២/២០១៩ | ១០០,០០០៛ | |
| វិភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយអំពីផលប្រយោជន៍ការបង់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលប្រាក់បង់ភាគទានប្រចាំឆ្នាំ | ១/១២/២០១៧ | ២៥/១២/២០១៩ | ១,០០០,០០០៛ | |
| ជំនួយសប្បុរសជន និងអង្គការនានា | បញ្ចូលផែនការអភិវឌ្ឍសហគមន៍ក្នុងកម្មវិធីវិនិយោគឃុំ/សង្កាត់ និងដាក់គម្រោងសំណើថវិកាទៅសប្បុរសជន និងអង្គការនានា | ១/៣/២០១៨ | ១/៦/២០១៩ | ១០០០,០០០៛ | |

### គ. ៦ ផែនការបង្កើនមុខរបរចិញ្ចឹមជីវិត

#### គ.៦.១ ការចិញ្ចឹមមាន់

| ចំនួនអ្នកចិញ្ចឹមមាន់ | សកម្មភាព | ចំនួនទ្រុងមាន់ | បរិមាណពូជមាន់ | ខែ/ ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ២៥គ្រួសារ | -ប្រជុំរៀបចំក្រុមចិញ្ចឹមមាន់ដែលជាសមាជិកមានជីវភាពក្រីក្រ<br>-បណ្តុះបណ្តាលបច្ចេកទេស និងឯកសារចិញ្ចឹមមាន់<br>-ផ្តល់ប្រាក់កម្ចីយកមាន់ចិញ្ចឹម<br>-ចូលរួមជួយធ្វើទ្រុងមាន់និងទិញពូជមាន់គាំទ្រសមាជិក សហគមន៍នេសាទ<br>-តាមដាន និងវាយតម្លៃការចិញ្ចឹមមាន់<br>-ផ្សព្វផ្សាយនិងគាំទ្រសមាជិកស.នផ្សេងចិញ្ចឹមបន្ត | ២៥ | ២៥០ | ២០១៨ | ២០១៩ |

#### គ.៦.២ ការធ្វើត្រីឆ្អើរ

| ចំនួនអ្នកធ្វើត្រីឆ្អើរ | សកម្មភាព | ប្រភេទត្រី | ខែ/ ឆ្នាំ | |
|---|---|---|---|---|
| | | | ចាប់ផ្តើម | ប្រមូលផល |
| ១០គ្រួសារ | - ប្រជុំរៀបចំក្រុមធ្វើត្រីឆ្អើរ | - ត្រីកញ្ចុះ<br>- ត្រីរៀល | ២០១៨ | ២០១៩ |

| | | | | |
|---|---|---|---|---|
| | - បណ្ដុះបណ្ដាលបច្ចេកទេសនិងឯកសារអំពីគុណភាពផ្អើរត្រី ។<br>- តាមដាន និង វាយតម្លៃសកម្មភាពផ្អើរត្រី។<br>- ប្រមូលប្រាក់ដើមពីសមាជិកសហគមន៍ដែលបានខ្ចីទិញត្រីធ្វើត្រីឆ្អើរ។<br>- ប្រជុំផ្សព្វផ្សាយ និងប្រគល់អោយសមាជិកសហគមន៍ខ្ចីបន្ត។ | - ត្រីក្រុស<br>- ត្រីតាអោន<br>- ត្រីកំភ្លាវ | | |

គ.៦.៤ ការធ្វើត្រីប្រហុក

| ចំនួនអ្នកធ្វើត្រីប្រហុក | សកម្មភាព | ប្រភេទត្រី | ខែ/ ឆ្នាំ | |
|---|---|---|---|---|
| | | | ចាប់ផ្ដើម | ប្រមូលផល |
| ២០គ្រួសារ | - ប្រជុំរៀបចំក្រុមធ្វើប្រហុក<br>- បណ្ដុះបណ្ដាលបច្ចេកទេសនិងឯកសារអំពីគុណភាព ប្រហុក។<br>- តាមដាន និងវាយតម្លៃសកម្មភាពធ្វើប្រហុក។<br>- ប្រមូលប្រាក់ដើមពីសមាជិកសហគមន៍ដែលបានខ្ចីទិញត្រីធ្វើប្រហុក។<br>- ប្រជុំផ្សព្វផ្សាយ និងប្រគល់អោយសមាជិកសហគមន៍ខ្ចីបន្ត ។ | - ត្រីរៀល<br>- ត្រីក្រុស | ២០១៨ | ២០១៩ |

## គ. ៧ ផែនការពង្រឹងសម្ថភាពគណៈកម្មការសហគមន៍នេសាទ

| ប្រភេទវគ្គបណ្ដុះបណ្ដាល | គ្រូបង្គោល | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|
| របៀបនៃការគ្រប់គ្រងសហគមន៍នេសាទ | រដ្ឋបាលជលផល | កក្កដា ២០១៧ | កក្កដា ២០១៨ | ៣ថ្ងៃ |
| វិធីសាស្ត្រផ្សព្វផ្សាយ | រដ្ឋបាលជលផល | សីហា ២០១៧ | សីហា ២០១៨ | ៣ថ្ងៃ |
| ការកសាងភាពជាដៃគូរ និងបណ្ដាញ | រដ្ឋបាលជលផល | កញ្ញា ២០១៧ | កញ្ញា ២០១៨ | ៣ថ្ងៃ |
| វិធីសាស្ត្រស្វែងថវិកា និងការសរសេរគម្រោងសំណើសុំថវិកា | រដ្ឋបាលជលផល | តុលា ២០១៧ | តុលា ២០១៨ | ៣ថ្ងៃ |
| ច្បាប់ស្ដីពីជលផល | រដ្ឋបាលជលផល | វិច្ឆិកា ២០១៧ | វិច្ឆិកា ២០១៨ | ៣ថ្ងៃ |
| វិធីសាស្ត្រដោះស្រាយទំនាស់ | រដ្ឋបាលជលផល | ធ្នូ ២០១៧ | ធ្នូ ២០១៨ | ៣ថ្ងៃ |

| | | | | |
|---|---|---|---|---|
| ជំនាញក្នុងការសម្របសម្រួល និងការតៀងគរសហគមន៍ | រដ្ឋបាលជលផល | មករា ២០១៨ | មករា ២០១៨ | ៣ថ្ងៃ |
| ជំនាញក្នុងការទំនាក់ទំនង | រដ្ឋបាលជលផល | កុម្ភៈ ២០១៨ | កុម្ភៈ ២០១៨ | ៣ថ្ងៃ |

គ. ៨ ផែនការទិញទូកម៉ាស៊ីនចុះល្បាត

| ល.រ | បរិយាយ | ឯកតា | ចំនួន | តម្លៃរាយ | តម្លៃសរុប | ថ្ងៃខែចាប់ផ្តើម | ថ្ងៃខែបញ្ចប់ |
|---|---|---|---|---|---|---|---|
| ១ | សំបកទូកបាឡាស្ទាច់<br>បណ្តោយៈ ៨,៥ម<br>ទទឹងៈ ១,៣ម | គ្រឿង | ១ | ៧៥០ | ៧៥០ | ៦/២០១៧ | ៦/២០១៧ |
| ២ | ម៉ាស៊ីនម៉ាកមួយទឹក | គ្រឿង | ១ | ១១៥០ | ១១៥០ | ៦/២០១៧ | ៦/២០១៧ |
| ៤ | ថ្លៃដឹកជញ្ជូន | | | ៤០ | ៤០ | | |
| តម្លៃសរុបទាំងអស់ | | | | | ១.៩៤០ដុល្លាអាមេរិក | | |

គ. ៩ ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ

| ល.រ | បរិយាយ | ឯកតា | ចំនួន | តម្លៃរាយ (ដុល្លា) | តម្លៃសរុប (ដុល្លា) | ថ្ងៃខែចាប់ផ្តើម | ថ្ងៃខែបញ្ចប់ |
|---|---|---|---|---|---|---|---|
| ១ | ទិញឬស្សីមូល | ដើម | ១០០ | ២ | ២០០ | ៦/២០១៨ | ១២/២០១៨ |
| ២ | ឈើលេខមួយ(គគី) | គូប | ៤ | ៤០០ | ១៦០០ | ៦/២០១៨ | ១២/២០១៨ |
| ៣ | ឈើលេខពីរ | គូប | ៤ | ២៥០ | ១០០០ | ៦/២០១៨ | ១២/២០១៨ |
| ៤ | ដែកសង្កសី | សន្លឹក | ៨០ | ៤ | ៣២០ | ៦/២០១៨ | ១២/២០១៨ |
| ៥ | ដែកគោល | សុង | ១០ | ៥ | ៥០ | ៦/២០១៨ | ១២/២០១៨ |
| ៦ | ដែកប៊ូឡុង ១០លី | ដើម | ៥០ | ២.៥ | ១២៥ | ៦/២០១៨ | ១២/២០១៨ |
| តម្លៃសរុបទាំងអស់ | | | | | ៣.២៩៥ដុល្លាអាមេរិក | | |

ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការអោយទទួលបានជោគជ័យយុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាននិងសមាជិកសហគមន៍នេសាទដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗជាពិសេសអំពីការគ្រប់គ្រងធនធានជលផល។
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ចដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផល ដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងថវិកាទ្រទ្រង់ជាដើម រៀបចំយុទ្ធសាស្ត្រទំនាក់

ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើការអនុវត្តផែនការ។

- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ។
- រៀចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់។
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជុំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ។
- គៀងគរអោយមានការការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ។
- រៀបចំវិធានទប់ស្កាត់ការការហូរចូលអ្នកនេសាទមកពីក្រៅសហគមន៍។
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ។
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ។
- បញ្ចូលផែនការការគ្រប់គ្រសហគមន៍នេសាទទៅក្នុផែនការអភិវឌ្ឍន៍ឃុំ។

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ជួនស្តើង រយៈពេល (២០១៧ ដល់ ២០១៩)**

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១.ការប្រើប្រាស់ឧបករណ៍នេសាទ | -ប្រជុំផ្សព្វផ្សាយស្តីពីការប្រើប្រាស់ឧបករណ៍នេសាទនៅតាមព្រៃកត្រពាំង និង អូរក្នុងកន្លែងនេសាទសហគមន៍។ | អ្នកនេសាទនឹងយល់ដឹងអំពីប្រភេទ ទំហំប្រវែងឧបករណ៍នេសាទដែលអនុញ្ញាតអោយប្រើប្រាស់ក្នុងកន្លែងនេសាទសហគមន៍។ | ៥០០ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និងគម្រោង EU-SIFAL | ២០១៧ | ២០១៩ | |
| ២. កំណត់ និងរៀបចំកន្លែងអភិរក្ស និងបោះបង្គោលក្នុងកន្លែងអភិរក្សព្រៃលិចទឹក និងត្រីមេពូជ | -ធ្វើស្លាកសញ្ញាកន្លែងអភិរក្សត្រីមេពូជ និងព្រៃលិចទឹក.<br>-ធ្វើ និងដាក់បង្គោលលូស៊ីម៉ង់ និងគល់ឈើក្នុងកន្លែងអភិរក្សត្រីមេពូជ (ជម្រកសប្បនិម្មិត).<br>-ធ្វើ និង បោះបង្គោលក្នុងកន្លែងអភិរក្សព្រៃលិចទឹក. | -នឹងមានស្លាកសញ្ញាកន្លែអភិរក្ស ត្រីមេពូជ និង ព្រៃលិចទឹក។<br>-នឹងមានបង្គោល លូ ស៊ីម៉ងតិ៍ និងគល់ឈើសម្រាប់ដាក់ក្នុងកន្លែងអភិរក្សត្រីមេពូជ។<br>-នឹងមានបង្គោលសម្រាប់បោះក្នុងកន្លែងអភិរក្សព្រៃលិចទឹក។ | ៣០០០ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និងគម្រោង SIFAL | ២០១៧ | ២០១៩ | |
| ៣. ផែនការគ្រប់គ្រងព្រៃលិចទឹក | -ធ្វើថ្នាលផ្សាំកូនដើមរាំង និងកូនដើមផ្តោល។<br>-រៀបចំកន្លែងដែលត្រូវដាំកូនដើមរាំង និងផ្តោល។<br>-ដាំដើមឈើចំនួន ១៥០០០ដើម។ | -នឹងបានបណ្តុះកូនដើមរាំង និងផ្តោល ចំនួន១៥០០០ដើម។<br>-នឹងបានដាំកូនដើមរាំង និងផ្តោល ចំនួន ១៥០០០ដើមនៅកន្លែងអភិរក្សព្រៃលិចទឹក។ | ១៨០០ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និងគម្រោង SIFAL | ២០១៧ | ២០១៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | - បង្កើតក្រុមចិញ្ចឹមត្រីអណ្តែង និងត្រីប្រា។<br>- ដឹកនាំ និងចូលរួមវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រីប្រា និងត្រីអណ្តែង។ | - ក្រុមចិញ្ចឹមត្រីប្រា និងត្រីអណ្តែងត្រូវបានបង្កើត។<br>- សហគមន៍នេសាទ នឹងមានចំណេះដឹងអំពីការចិញ្ចឹមត្រីប និងត្រីអណ្តែង។ | ១៥០០ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និងគម្រោង SIFAL | ២០១៧ | ២០១៩ | |
| ៥. ផែនការរកចំណូលសហគមន៍ | ដឹកនាំផ្សព្វផ្សាយ និងប្រមូលប្រាក់វិភាគទានប្រចាំឆ្នាំ និងរៀបចំគម្រោងផែនការស្នើសុំថវិកាសម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ។ | - សមាជិកសហគមន៍នេសាទទាំងអស់នឹងបានបង់ប្រាក់វិភាគទានប្រចាំឆ្នាំដោយស្ម័គ្រចិត្ត។<br>- គណៈកម្មការសហគមន៍នេសាទនឹងបានរៀបចំធ្វើគម្រោងផែនការស្នើសុំថវិកាពីគម្រោង ឬអង្គការនានា។ | ៥០០០ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និងគម្រោង SIFAL | ២០១៧ | ២០១៩ | |
| ៦. ផែនការបង្កើនមុខរបរចិញ្ចឹមជីវិត | - បង្កើតក្រុមចិញ្ចឹមជ្រូកនិងមាន់។<br>- ដឹកនាំ និងចូលរួមវគ្គបណ្តុះ។ បណ្តាលអំពីបច្ចេកទេស បង្កើនមុខរបរចិញ្ចឹមជីវិតសមស្រប។ | - ក្រុមបង្កើនមុខរបរចិញ្ចឹមជីវិត នឹងត្រូវបានបង្កើតតាមជំរើសមុខរបរ សមស្រប<br>- សហគមន៍នេសាទនឹងមានចំណេះដឹងអំពីមុខរបរចិញ្ចឹមជីវិតសមស្រប | ៣០០០ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និងគម្រោង SIFAL | ២០១៧ | ២០១៩ | |
| ៧. ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ | - ចូលរួមបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសហគមន៍នេសាទ វិធីផ្សព្វផ្សាយ, វិធីសាស្ត្រស្វែងរកថវិកា និងការសរសេរគម្រោងសំណើសុំថវិកា, ច្បាប់ស្តីពីជលផល, ជំនាញក្នុងការសម្របសម្រួល និង | - សហគមន៍នឹងមានចំណេះដឹង និងពង្រឹងសមត្ថភាពបន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាល។ | ៣០០ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និងគម្រោង SIFAL | ២០១៧ | ២០១៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ការតៀងគរអោយមានការចូលរួមក្នុងសហគមន៍។ | | | | | | |
| ៨. ផែនការទិញទូកម៉ាស៊ីនល្បាត | - ទិញទូកកាណូត និងម៉ាស៊ីនសម្រាប់ចុះល្បាត។ | - មានទូកកាណូតសម្រាប់ចុះល្បាត។ | ២០០០ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និងគម្រោងSIFAL | ២០១៧ | ២០១៩ | |
| ៩. ផែនការសាងសង់សហគមន៍នេសាទ | - ទិញឈើ និងសម្ភារៈសម្រាប់ធ្វើស្នាក់ការ។<br>- ដឹកនាំធ្វើស្នាក់ការសហគមន៍។ | - មានស្នាក់ការសហគមន៍នេសាទ។ | ៤០៩៥ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និងគម្រោង SIFAL | ២០១៧ | ២០១៩ | |
| ១០.ចុះល្បាត | - បង្កើតក្រុមល្បាត<br>- រៀបចំផែនការចុះល្បាត<br>- ទិញសម្ភារៈគាំទ្រការចុះល្បាត ចុះល្បាតជាទៀងទាត់។ | - ក្រុមល្បាតបានបង្កើតដោយមានតំណាងក្រុមយ៉ាងហោចណាស់៥នាក់ក្នុងមួយក្រុម និងមាន៥ក្រុម។<br>- ផែនការចុះល្បាតនិងត្រូវបានរៀបចំដោយគណៈកម្មការសហគមន៍និងតំណាងក្រុមល្បាត។<br>- សម្ភារៈល្បាតនឹងទិញដើម្បីគាំទ្រចុះល្បាត<br>- សហគមន៍ចុះល្បាតជាទៀងទាត់៤ដងក្នុងមួយខែ។ | ១០០០ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និងគម្រោង SIFAL | ២០១៧ | ២០១៩ | |
| ១១.ប្រជុំប្រចាំខែគណៈកម្មការសហគមន៍ | - ប្រជុំគណៈកម្មការសហគមន៍នេសាទប្រចាំខែ។ | - គណៈកម្មការនិងរៀបចំប្រជុំប្រចាំខែរៀងរាល់ខែដើម្បីបង្ហាញពីភាពរីកចម្រើន បញ្ហា | ៣៦០ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និងគម្រោង SIFAL | ២០១៧ | ២០១៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ប្រឈម ដំណោះស្រាយនិងរៀបចំផែនការសកម្មភាពសម្រាប់ខែបន្ទាប់។ | | | | | |
| ១២.ប្រជុំប្រចាំត្រីមាសជាមួយក្រុមប្រឹក្សាឃុំ | -ប្រជុំគណៈកម្មការសហគមន៍នេសាទប្រចាំត្រីមាស។ | -គណៈកម្មការនឹងរៀបចំកិច្ចប្រជុំប្រចាំត្រីមាសរយៈពេល៣ខែម្តងដើម្បីបូកសរុបលទ្ធផលការងារ និងលើកផែនការត្រីមាសបន្ទាប់ ។ | ២៤០ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និងគម្រោង SIFAL | ២០១៧ | ២០១៩ | |

## ភាពសង្ខេបការងារ

| សកម្មភាព | ការបរិច្ឆេទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2017 | | | | | | | 2018 | | | | | | | | | | | | | 2019 | | | | | | | | | | |
| | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១. ការប្រើប្រាស់ ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២. ការកំណត់ និងរៀបចំកន្លែងអភិរក្ស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣ .ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥. ផែនការរកចំណូលសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦. ផែនការបង្កើតមុខរបរចិញ្ចឹមជីវិត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧. ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៨. ផែនការទិញទូកម៉ាស៊ីនល្បាត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៩. ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១០. ចុះល្បាត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១១. ប្រជុំប្រចាំខែគណៈកម្មការ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១២. ប្រជុំប្រចាំត្រីមាសជាមួយក្រុមប្រឹក្សាឃុំ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១៣. ផែនការប្រជុំប្រចាំឆ្នាំរបស់សហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

លេខ:........................
បានឃើញនិងគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ
"ដើម្បីជូនពិនិត្យនិងសម្រួល"
..........ថ្ងៃទី២៥.....ខែកក្កដា ឆ្នាំ២០១៧
**នាយផ្នែករដ្ឋបាលជលផលផាត់សណ្តាយ**

បានឃើញនិងគោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលផាត់សណ្តាយ
"ដើម្បីជូនពិនិត្យនិងសម្រួល"
ពាមបាង.....ថ្ងៃទី២៥.....ខែកក្កដា ឆ្នាំ២០១៧
**នាយសង្កាត់រដ្ឋបាលជលផលពាមបាង**

លេខ:........................
បានឃើញនិងគោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផលពាមបាង
"ដើម្បីជូនពិនិត្យនិងសម្រួល"
...........ថ្ងៃទី២៤ ខែ០៧ ឆ្នាំ២០១៧
**មេឃុំ**
**សុខា**

សូមគោរពជូន
**លោកមេឃុំពាមបាង**
"ដើម្បីជូនពិនិត្យនិងសម្រួល"
.........ថ្ងៃទី២៤ ខែ០៧ ឆ្នាំ២០១៧
ប្រធានគណៈកម្មការសហគមន៍នេសាទ
**ជូនស្មើង**

លេខ៣១១៣...ជផ
បានឃើញនិងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី០៤... ខែតុលា...ឆ្នាំ២០១៧
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**

លេខ :១៩៦២...មកស.ជប
បានឃើញនិងគោរពជូន
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
"ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ"
កំពង់ធំថ្ងៃទី១១....ខែសីហា ឆ្នាំ២០១៧
**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**-ខេត្តកំពង់ធំ-**

**ជីវ វណ្ណធីរ**

លេខ :២៦៤....ខណ.ជផ
បានឃើញនិងគោរពជូន
លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ខេត្តកំពង់ធំ-
"ដើម្បីជូនពិនិត្យនិងសម្រួល"
កំពង់ធំ ថ្ងៃទី០៤...ខែសីហា ឆ្នាំ២០១៧
**នាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ**

**ប៉ើន_ចន្ថារិទ្ធ**